# សំណួរដែលគេសួរញឹកញាប់អំពីទិដ្ឋការ និងអន្តោប្រវេសន៍ទាក់ទងនឹងជំងឺរលាកថ្លើមប្រភេទ B



ឯកសារណែនាំទូទៅសម្រាប់បុគ្គលដែលរស់នៅជាមួយជំងឺរលាកថ្លើមប្រភេទ B ឬអ្នកដែលស្គាល់នរណាម្នាក់ដែលរស់នៅជាមួយ ឬរងផលប៉ះពាល់ដោយជំងឺរលាកថ្លើមប្រភេទ B ឬក៏អ្នកដែលកំពុងស្វែងរកព័ត៌មានទូទៅអំពីឯកសារនានាស្តីពីទិដ្ឋាការដែលទាក់ទងនឹងជំងឺរលាកថ្លើមប្រភេទ B។

hepatitis australia

LiverWELL Incorporating HEPATITIS VICTORIA

## អំពីទំព័រនេះ

ទំព័រនេះមានគោលបំណងប្រើជាឯកសារណែនាំទូទៅមួយសម្រាប់បុគ្គលដែលរស់នៅជាមួយជំងឺរលាកថ្លើមប្រភេទ B ឬអ្នកដែលស្គាល់នរណាម្នាក់រស់នៅជាមួយ ឬរងផលប៉ះពាល់ដោយជំងឺរលាកថ្លើមប្រភេទ B ឬក៏អ្នកដែលស្វែងរកព័ត៌មានទូទៅអំពីឯកសារនានាស្ដីពីទិដ្ឋាការទាក់ទងនឹងជំងឺរលាកថ្លើមប្រភេទ B។ យើងផ្តល់យោបល់ឱ្យអ្នកគួរពិភាក្សាជាមួយភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះបញ្ជីស្របច្បាប់ ឬមេធាវីអំពីស្ថានភាពជាក់លាក់របស់អ្នក និងដើម្បីទទួលបានដំបូន្មានទៅតាមស្ថានភាពរបស់អ្នក។ លើសពីនេះ បុគ្គលទាំងឡាយគួរនិយាយជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់ពួកគេ ដើម្បីទទួលបានដំបូន្មានពីគ្រូពេទ្យស្តីពីការគ្រប់គ្រងជំងឺរលាកថ្លើមប្រភេទ B និងដើម្បីធានាថាពួកគេទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រសមស្រប។

ព័ត៌មានគឺត្រឹមត្រូវនៅពេលនៃការបោះពុម្ពផ្សាយ (ខែសីហា ឆ្នាំ 2025 បានពិនិត្យឡើងវិញចុងក្រោយនៅខែមករា ឆ្នាំ 2025) ប៉ុន្តែអាចអាស្រ័យទៅលើការផ្លាស់ប្តូរ។ យើងដាក់ឯកសារបោះពុម្ពនេះសម្រាប់ការប្រើប្រាស់ជាសាធារណៈ ដោយយល់ថា ដោយបានផ្តល់ព័ត៌មាននេះមែន តែអ្នកនិពន្ធ ឬអង្គការនានាមិនចូលរួមក្នុងការផ្តល់ដំបូន្មានប្រកបដោយវិជ្ជាជីវៈនោះទេ។

## អំពី HepLink Australia

HepLink Australia ផ្តល់ព័ត៌មានអំពីជំងឺរលាកថ្លើមដោយមេរោគ ដំបូន្មាន និងសេវាកម្មគាំទ្រដល់នរណាម្នាក់ដោយឥតគិតថ្លៃ និងសម្ងាត់ នៅគ្រប់ទីកន្លែងក្នុងប្រទេសអូស្ត្រាលី។ HepLink ត្រូវបានផ្តល់មូលនិធិដោយរដ្ឋាភិបាលអូស្ត្រាលី។

ហៅទូរសព្ទទៅលេខ 1800 437 222 ឬចូលមើលគេហទំព័រ www.heplink.au

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ សូមហៅទូរសព្ទទៅ TIS National តាមលេខ 131 450 ហើយសុំឱ្យពួកគេហៅទូរសព្ទទៅ HepLink Australia តាមលេខ 1800 437 222។ ម៉ោងធ្វើការរបស់យើងគឺ 9 ព្រឹក ដល់ 5 ល្ងាច ថ្ងៃចន្ទ ដល់ថ្ងៃ សុក្រ

អ្នកក៏អាចចូលមើលគេហទំព័រ TIS National សម្រាប់ព័ត៌មានដែលបានបកប្រែអំពីសេវាដែលផ្តល់ដោយ TIS National។ ចូលមើល៖ www.tisnational.gov.au





# មាតិកា

សទ្ទានុក្រម 4
លក្ខខណ្ឌតម្រូវសុខភាពសម្រាប់ទិដ្ឋាការ 6
អំពីលក្ខខណ្ឌតម្រូវសុខភាពសម្រាប់ទិដ្ឋាការ និងជំងឺរលាកថ្លើមប្រភេទ B 6
លក្ខខណ្ឌតម្រូវនៃទិដ្ឋាការ - សំណួរដែលគេសួរញឹកញាប់ 7
អំពីការពិនិត្យសុខភាព 9
ការពិនិត្យសុខភាព - សំណួរដែលគេសួរញឹកញាប់ 10
ឱសថ - សំណួរដែលគេសួរញឹកញាប់ 11
ការធ្វើការនៅប្រទេសអូស្ត្រាលី - សំណួរដែលគេសួរញឹកញាប់ 13
ដំបូន្មានផ្នែកច្បាប់ 14

# សទ្ទានុក្រម

**កងកម្លាំងការពារប្រទេសអូស្ត្រាលី៖**
អង្គការយោធាដែលទទួលខុសត្រូវចំពោះការការពារកុំម៉ន់វេលអូស្ត្រាលី (Commonwealth of Australia) និងផលប្រយោជន៍ជាតិរបស់អូស្ត្រាលី។[1]

**សេវាពិនិត្យសុខភាពសម្រាប់ទិដ្ឋាការរបស់ Bupa (Bupa Medical Visa Services)៖**
សេវាសុខភាពមួយដែលចាត់ចែង និងគ្រប់គ្រងមជ្ឈមណ្ឌលវេជ្ជសាស្ត្រនានានៅជុំវិញប្រទេសអូស្ត្រាលីតាងនាមឱ្យក្រសួងអន្តោប្រវេសន៍ ដើម្បីផ្តល់ការពិនិត្យសុខភាពដល់អ្នកដាក់ពាក្យសុំទិដ្ឋាការ។[2]

**ក្រសួងមហាផ្ទៃ៖**
ក្រសួងមហាផ្ទៃរបស់រដ្ឋាភិបាលអូស្ត្រាលីដែលមានមុខងារទំនួលខុសត្រូវចំពោះសន្តិសុខជាតិ សេវាការពារ ការគ្រប់គ្រងគ្រាអាសន្ន ការគ្រប់គ្រងព្រំដែន អន្តោប្រវេសន៍ ជនភៀសខ្លួន សញ្ជាតិ សន្តិសុខការដឹកជញ្ជូន និងកិច្ចការពហុវប្បធម៌។[3]

**ទិដ្ឋាការអ្នករស់នៅក្នុងបន្ទុក៖**
(ជួនកាលគេហៅថា ទិដ្ឋាការគ្រួសារ) គឺជាប្រភេទទិដ្ឋាការដែលអនុញ្ញាតឱ្យសមាជិកគ្រួសារចូលរួមជាមួយអ្នក ប្រសិនបើអ្នកមកប្រទេសអូស្ត្រាលីដើម្បីធ្វើការ ឬសិក្សាជាបណ្តោះអាសន្ន។[4]

**នីតិវិធីពេលមានការប៉ះពាល់អាចកើតឡើង (Exposure-Prone Procedures)៖**
នីតិវិធីដែលបុគ្គលិកថែទាំសុខភាពមានហានិភ័យរងរបួស ដែលបណ្តាលឱ្យមុខរបួសចំហរបស់អ្នកជំងឺប៉ះនឹងឈាមចេញពីមុខរបួសរបស់បុគ្គលិកថែទាំសុខភាព។[5]

**បុគ្គលិកថែទាំសុខភាពខាងផ្នែកវេជ្ជសាស្ត្រ (HCW)៖**
អ្នកដែលផ្តល់ការថែទាំ និងសេវាកម្មនានាដល់អ្នកឈឺ និងអ្នកមានសុខភាពទ្រុឌទ្រោម ដោយផ្ទាល់ដូចជាវេជ្ជបណ្ឌិត និងគិលានុបដ្ឋាក ឬដោយប្រយោលដូចជាអ្នកជំនួយការ អ្នកជំនួយ អ្នកបច្ចេកទេសមន្ទីរពិសោធន៍ ឬសូម្បីតែអ្នកគ្រប់គ្រងកាកសំណល់វេជ្ជសាស្ត្រ។[6]

**វីរុសជំងឺរលាកថ្លើមប្រភេទ B៖**
គឺជាការឆ្លងរោគមួយដែលអាចបណ្តាលឱ្យមានរលាកថ្លើម ក្រិនថ្លើម ជំងឺខូចថ្លើមធ្ងន់ធ្ងរ និងជំងឺមហារីកថ្លើម។[7]

**Hepatitis B Voices Australia៖**
ជាអង្គការជំងឺរលាកថ្លើមប្រភេទ B ដំបូងបង្អស់នៅក្នុងប្រទេសអូស្ត្រាលី ដឹកនាំទាំងស្រុងដោយអ្នករស់នៅ ឬរងការប៉ះពាល់ដោយជំងឺរលាកថ្លើមប្រភេទ B[8]

**ដំបូន្មានផ្នែកច្បាប់៖**
ការផ្តល់យោបល់ប្រកបដោយវិជ្ជាជីវៈ ឬផ្លូវការទាក់ទងនឹងខ្លឹមសារ ឬនីតិវិធីច្បាប់ទាក់ទងនឹងស្ថានភាពជាក់ស្តែងមួយ។[9,10]

**ការផ្សាំ៖**
ការវះកាត់ដើម្បីប្តូរថ្លើមដែលខូចចេញ ហើយជំនួសដោយថ្លើមដែលដំណើរការបានមកពីមនុស្ស ឬអ្នកបរិច្ចាគផ្សេងទៀត។[11]

**LiverWELL៖**
ជាអង្គការមិនរកកម្រៃដែលធ្វើការដើម្បីគាំទ្របុគ្គលនានាដែលរងប៉ះពាល់ដោយ ឬមានហានិភ័យដែលបណ្តាលឱ្យមានរោគរលាកថ្លើមដែលបង្កដោយវីរុស និងជំងឺថ្លើម។[12]

**អ្នកជំនាញវេជ្ជសាស្ត្រ៖**
ជាបុគ្គលដែលអនុវត្តវិជ្ជាជីវៈសុខាភិបាល (ឧទាហរណ៍ វេជ្ជបណ្ឌិត) ហើយបានចុះបញ្ជីក្រោមច្បាប់ជាតិស្តីពីបទប្បញ្ញត្តិគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល។[13]

**ធ្លាក់ម្នាក់ ធ្លាក់ទាំងអស់៖**
ជាលក្ខខណ្ឌតម្រូវដែលចែងថាអ្នកដាក់ពាក្យទាំងអស់នៅក្រោមទិដ្ឋាការរួមគ្នាជាមួយក្រុមគ្រួសារ ត្រូវតែបំពេញតាមលក្ខណៈវិនិច្ឆ័យសុខភាព។ ប្រសិនបើសមាជិកម្នាក់នៃក្រុមគ្រួសារមិនបំពេញតាមលក្ខណៈវិនិច្ឆ័យសុខភាព (ទោះជាលក្ខណៈវិនិច្ឆ័យដើម្បីផលប្រយោជន៍សាធារណៈ “PIC” លេខ 4005 ឬក៏ 4007 អាស្រ័យលើប្រភេទរងនៃទិដ្ឋាការ) ក្រសួងអាចនឹងបដិសេធពាក្យសុំទាំងមូល។

**ទិដ្ឋាការអចិន្ត្រៃយ៍៖**
ជាប្រភេទនៃទិដ្ឋាការដែលអនុញ្ញាតឱ្យអ្នកកាន់ទិដ្ឋាការបន្តការស្នាក់នៅដោយគ្មាន[14]

**ការធានារ៉ាប់រងសុខភាពឯកជន៖**
ជាគោលការណ៍មួយ ដែលរ៉ាប់រងលើការចំណាយមួយចំនួនក្នុងការព្យាបាលនៅគ្លីនិក ឬមន្ទីរពេទ្យក្នុងនាមជាអ្នកជំងឺឯកជនម្នាក់។ វាក៏អាចជួយបង់ថ្លៃថែទាំសុខភាពដែល Medicare មិនរ៉ាប់រងផងដែរ។[15]

**វេជ្ជបញ្ជា៖**
ការណែនាំជាលាយលក្ខណ៍អក្សររបស់គ្រូពេទ្យ ដែលអនុញ្ញាតឱ្យអ្នកជំងឺទទួលបានថ្នាំពេទ្យ ឬការព្យាបាល។[16]

**អ្នកចេញវេជ្ជបញ្ជាតាមផ្នែកទី s100៖**
វេជ្ជបណ្ឌិតទូទៅ គ្រូពេទ្យនៅតាមសហគមន៍ ឬគិលានុបដ្ឋាយិកា (Nurse practitioner) ដែលបានបញ្ចប់វគ្គសិក្សាជំនាញហើយមានសិទ្ធិចេញវេជ្ជបញ្ជាសម្រាប់ទិញថ្នាំព្យាបាលជំងឺរលាកថ្លើមប្រភេទ B ។[17]

**ទិដ្ឋាការបណ្តោះអាសន្ន៖**
ជាប្រភេទនៃទិដ្ឋាការដែលអនុញ្ញាតឱ្យអ្នកកាន់ទិដ្ឋាការស្នាក់នៅក្នុងរយៈពេលជាក់លាក់មួយ ស្នាក់នៅរហូតដល់អ្នកកាន់ទិដ្ឋាការមានស្ថានភាពបញ្ជាក់ច្បាស់។[18]

**បន្ទុកវីរុស៖**
ជាបរិមាណវីរុសដែលមាននៅក្នុងឈាមរបស់អ្នកដែលមានជំងឺរលាកថ្លើមប្រភេទ B ឬជំងឺរលាកថ្លើមប្រភេទ C។[19]



# លក្ខខណ្ឌតម្រូវសុខភាពសម្រាប់ទិដ្ឋាការ

អ្នកដាក់ពាក្យសុំទិដ្ឋាការភាគច្រើនត្រូវតែបំពេញតាមលក្ខខណ្ឌតម្រូវសុខភាព ដែលកំណត់ដោយច្បាប់អន្តោប្រវេសន៍អូស្ត្រាលីសម្រាប់ការចេញទិដ្ឋាការ ឬស្ថានភាពអន្តោប្រវេសន៍ផ្សេងទៀត។ ក្រសួងមហាផ្ទៃទទួលខុសត្រូវខាងពិនិត្យ និងធ្វើសេចក្ដីសម្រេចលើទិដ្ឋាការ។ ទំនួលខុសត្រូវនេះក៏រួមបញ្ចូលផងដែរនូវការកំណត់ថាតើការចំណាយប្រាក់នានាដែលទាក់ទងនឹងការព្យាបាល និងការគាំទ្រអ្នកដែលរស់នៅជាមួយស្ថានភាពសុខភាពហ្នឹងនឹងបណ្ដាលឱ្យមាន "ការចំណាយប្រាក់ដ៏ច្រើន" ដល់សហគមន៍អូស្ត្រាលី ឬភាពលំអៀងក្នុងការទទួលបានសេវានានាសម្រាប់ពលរដ្ឋអូស្ត្រាលីបច្ចុប្បន្ន និងអ្នករស់នៅអចិន្ត្រៃយ៍។ ប្រសិនបើតម្លៃប៉ាន់ស្មាននៃសេវាសុខភាព ឬសេវាសហគមន៍លើសពី 'កម្រិតចំណាយប្រាក់ដ៏ច្រើន' រដ្ឋាភិបាលអាចបដិសេធពាក្យសុំទិដ្ឋាការ។ លើសពីនេះទៀត ជាផ្នែកនៃលក្ខខណ្ឌតម្រូវសុខភាព ក្រសួងមហាផ្ទៃនឹងវាយតម្លៃថាតើបុគ្គលម្នាក់អាចបង្កហានិភ័យសុខភាពសាធារណៈដល់សហគមន៍អូស្ត្រាលីដែរឬទេ។ មានដំណើរការមួយចំនួនដែលកំពុងអនុវត្តសម្រាប់ការពិនិត្យឡើងវិញលើការធ្វើសេចក្ដីសម្រេចទាក់ទងនឹងពាក្យសុំទិដ្ឋាការ ហើយមានទិដ្ឋាការមួយចំនួនតូចអនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំស្នើសុំ "ការលើកលែង" នៃលក្ខខណ្ឌតម្រូវសុខភាពនោះបាន។

សម្រាប់ព័ត៌មានច្រើនទៀត សូមចូលមើល Meeting our health requirement នៅ immi.homeaffairs.gov.au

# អំពីលក្ខខណ្ឌតម្រូវសុខភាពសម្រាប់ទិដ្ឋាការ និងជំងឺរលាកថ្លើមប្រភេទ B

ពីមុន ក្រសួងបានបដិសេធទិដ្ឋាការរបស់អ្នកដាក់ពាក្យសុំមួយចំនួនដែលរស់មានជំងឺរលាកថ្លើមប្រភេទ B ដោយផ្អែកលើការចំណាយប្រាក់នានាដែលទាក់ទងនឹងការព្យាបាលជំងឺរលាកថ្លើមប្រភេទ B។ តែជាមួយនឹងការផ្លាស់ប្ដូរថ្មីៗចំពោះកម្រិតចំណាយប្រាក់ និងការកាត់បន្ថយតម្លៃថ្នាំព្យាបាលជំងឺរលាកថ្លើមប្រភេទ B នៅក្នុងប្រទេសអូស្ត្រាលី មានន័យថាបច្ចុប្បន្នអ្នកដាក់ពាក្យសុំទិដ្ឋាការភាគច្រើនដែលមានជំងឺរលាកថ្លើមប្រភេទ B រួមទាំងអ្នកដែលកំពុងព្យាបាល មិនជាបញ្ហាក្នុងការបំពេញលក្ខខណ្ឌតម្រូវសុខភាពសម្រាប់ទិដ្ឋាការ ដោយសារតែស្ថានភាពជំងឺរលាកថ្លើមប្រភេទ B និងតម្លៃព្យាបាលរំពឹងទុកទៀតទេ។ ទោះជាយ៉ាងណា អ្នកដាក់ពាក្យសុំនៅតែត្រូវបំពេញតាមលក្ខខណ្ឌទិដ្ឋាការផ្សេងទៀតទាំងអស់ផងដែរ។

ជាទូទៅ ជំងឺរលាកថ្លើមប្រភេទ B មិនត្រូវបានចាត់ទុកថាជាការគំរាមកំហែងសុខភាពសាធារណៈចំពោះសហគមន៍អូស្ត្រាលីនោះទេ បើយោងទៅតាមច្បាប់អន្តោប្រវេសន៍។ ទោះយ៉ាងណាក៏ដោយ អ្នកដាក់ពាក្យសុំដែលមានបំណងចង់សិក្សា ឬធ្វើការជាវេជ្ជបណ្ឌិត គិលានុបដ្ឋាក ទន្តបណ្ឌិត ឬគ្រូពេទ្យសង្គ្រោះបន្ទាន់ (បុគ្គលិកខាងផ្នែកវេជ្ជសាស្ត្រ) តម្រូវឱ្យផ្ដល់ព័ត៌មានបន្ថែម និង/ឬបំពេញលក្ខខណ្ឌតម្រូវបន្ថែមនៅពេលដាក់ពាក្យសុំទិដ្ឋាការ (សូមមើលខាងក្រោម៖ “ខ្ញុំមានជំងឺរលាកថ្លើមប្រភេទ B ហើយខ្ញុំកំពុងមានគម្រោងទៅសិក្សានៅប្រទេសអូស្ត្រាលី។ តើរឿងនេះនឹងប៉ះពាល់ដល់ការដាក់ពាក្យសុំទិដ្ឋាការរបស់ខ្ញុំដែរឬទេ?')

ខណៈដែលការផ្លាស់ប្ដូរទាំងនេះជាទូទៅមានភាពវិជ្ជមានសម្រាប់អ្នកដាក់ពាក្យសុំដែលរស់នៅមានជំងឺរលាកថ្លើមប្រភេទ B ក្រសួងអាចពិចារណាលើស្ថានភាពសុខភាពជាច្រើនប្រភេទផ្សេងទៀតដែលពាក់ព័ន្ធនឹងការវាយតម្លៃនៃលក្ខខណ្ឌសុខភាព។ នេះមានន័យថា អ្នកដាក់ពាក្យសុំទិដ្ឋាការដែលរស់នៅជាមួយជំងឺរលាកថ្លើមប្រភេទ B និងកំពុងរស់នៅមានស្ថានភាពសុខភាពផ្សេងទៀត ឬជំងឺរលាកថ្លើមប្រភេទ B របស់ពួកគេត្រូវការការគ្រប់គ្រងស្មុគស្មាញ អាចនឹងមិនបំពេញទៅតាមលក្ខខណ្ឌសុខភាពដែលពាក់ព័ន្ធនោះទេ។

# លក្ខខណ្ឌតម្រូវនៃទិដ្ឋាការ - សំណួរដែលគេសួរញឹកញាប់

## តើខ្ញុំនឹងទទួលការបដិសេធទិដ្ឋាការបណ្ដោះអាសន្នដោយសារស្ថានភាពជំងឺរលាកថ្លើមប្រភេទ B របស់ខ្ញុំដែរឬទេ?

អ្នកដាក់ពាក្យសុំទិដ្ឋាការភាគច្រើនដែលមានជំងឺរលាកថ្លើមប្រភេទ B នឹងមិនជាបញ្ហាក្នុងការបំពេញតាមតម្រូវការសុខភាពនៅពេលដាក់ពាក្យសុំទិដ្ឋាការបណ្ដោះអាសន្នទៅកាន់ប្រទេសអូស្ត្រាលី ដោយសារស្ថានភាពជំងឺរលាកថ្លើមប្រភេទ B របស់ពួកគេ និងតម្លៃព្យាបាលរំពឹងទុកនោះទេ។ ដូចដែលក្រសួងមហាផ្ទៃបានរៀបរាប់ ក្នុងកាលៈទេសៈខ្លះ អាចមានជំហាន ឬលក្ខខណ្ឌតម្រូវបន្ថែមសម្រាប់អ្នកដាក់ពាក្យសុំទិដ្ឋាការបណ្ដោះអាសន្នដែលមានជំងឺរលាកថ្លើមប្រភេទ B និងកំពុងមានគម្រោងទៅសិក្សា ឬធ្វើការជាបុគ្គលិកថែទាំសុខភាពដូចជាវេជ្ជបណ្ឌិត គិលានុបដ្ឋាក ទន្តពេទ្យ ឬគ្រូពេទ្យសង្គ្រោះបន្ទាន់។

(សូមមើលផ្នែកខាងក្រោម 'ខ្ញុំមានជំងឺរលាកថ្លើមប្រភេទ B ហើយខ្ញុំកំពុងមានគម្រោងទៅសិក្សានៅប្រទេសអូស្ត្រាលី។ តើរឿងនេះនឹងប៉ះពាល់ដល់ការដាក់ពាក្យសុំទិដ្ឋាការរបស់ខ្ញុំដែរឬទេ?') តើរឿងនេះនឹងប៉ះពាល់ដល់ការដាក់ពាក្យសុំទិដ្ឋាការរបស់ខ្ញុំដែរឬទេ?')

## តើខ្ញុំនឹងទទួលការបដិសេធការតាំងលំនៅអចិន្ត្រៃយ៍ដោយសារស្ថានភាពជំងឺរលាកថ្លើមប្រភេទ B របស់ខ្ញុំដែរឬទេ?

អ្នកដាក់ពាក្យសុំភាគច្រើនដែលមានជំងឺរលាកថ្លើមប្រភេទ B អាចនឹងមិនជាបញ្ហាក្នុងការបំពេញតាមលក្ខខណ្ឌសុខភាពនៅពេលដាក់ពាក្យសុំទិដ្ឋាការអចិន្ត្រៃយ៍នោះទេ។ នេះរួមបញ្ចូលទាំងអ្នកមានជំងឺរលាកថ្លើមប្រភេទ B ដែលត្រូវការការព្យាបាល។

ទោះជាយ៉ាងណាក៏ដោយ លក្ខខណ្ឌតម្រូវសុខភាពសម្រាប់ទិដ្ឋាការនីមួយៗអាចពិចារណាលើលក្ខខណ្ឌសុខភាពជាច្រើនផ្សេងទៀត ដែលពាក់ព័ន្ធនឹងការវាយតម្លៃរបស់ខ្លួន។ នេះមានន័យថា អ្នកដាក់ពាក្យសុំដែលមានជំងឺរលាកថ្លើមប្រភេទ B ដែលមានលក្ខខណ្ឌសុខភាពផ្សេងទៀត ឬជំងឺរលាកថ្លើមប្រភេទ B របស់ពួកគេត្រូវការការគ្រប់គ្រងស្មុគស្មាញ អាចនឹងមិនបំពេញតាមលក្ខខណ្ឌតម្រូវសុខភាពដែលពាក់ព័ន្ធនោះទេ។

ហេតុដូច្នេះហើយ អ្នកដាក់ពាក្យសុំចាំបាច់ត្រូវស្វែងរកដំបូន្មានទៅតាមស្ថានភាពពីភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះបញ្ជីស្របច្បាប់ ឬមេធាវីអំពីថា តើជំងឺរលាកថ្លើមប្រភេទ B និងលក្ខខណ្ឌសុខភាពផ្សេងទៀតរបស់ពួកគេប៉ះពាល់អ្វីខ្លះទៅលើពាក្យសុំទិដ្ឋាការរបស់ពួកគេ។ នៅមុនពេលដាក់ពាក្យសុំទិដ្ឋាការ វាជារឿងសំខាន់ត្រូវពិភាក្សាអំពីផែនការ ឬយុទ្ធសាស្ត្រសមស្របមួយសម្រាប់ការដាក់ពាក្យសុំទិដ្ឋាការ និងផ្លូវទៅកាន់ការតាំងលំនៅអចិន្ត្រៃយ៍។

## តើមានផលប៉ះពាល់ដល់ការស្នាក់នៅរបស់ខ្ញុំក្នុងប្រទេសអូស្ត្រាលីដែរឬទេ ប្រសិនបើគ្រូពេទ្យធ្វើរោគវិនិច្ឆ័យឃើញថាខ្ញុំមានជំងឺរលាកថ្លើមប្រភេទ B?

ការធ្វើរោគវិនិច្ឆ័យនៃជំងឺរលាកថ្លើមប្រភេទ B មិនបណ្ដាលឱ្យមានការលុបចោលទិដ្ឋាការបច្ចុប្បន្នរបស់អ្នក ឬប៉ះពាល់ដល់ការស្នាក់នៅក្នុងប្រទេសអូស្ត្រាលីនោះទេ។ ទោះជាយ៉ាងណាក៏ដោយ វាជារឿងសំខាន់ក្នុងការបញ្ជាក់ថា ប្រសិនបើអ្នកមានជំងឺរលាកថ្លើមប្រភេទ B នោះការទទួលបានការថែទាំជាប្រចាំគឺមានសារៈសំខាន់ដើម្បីការពារសុខភាពរបស់អ្នក។ ការធ្វើរោគវិនិច្ឆ័យបានទាន់ពេល និងការគ្រប់គ្រងជាបន្តអាចកាត់បន្ថយបានច្រើននូវហានិភ័យនៃផលវិបាកធ្ងន់ធ្ងរ ដូចជាជំងឺក្រិនថ្លើម ឬជំងឺថ្លើមដំណាក់កាលចុងក្រោយ។ ជៀសវាងរោគវិនិច្ឆ័យ និងការថែទាំអាចបង្កើនហានិភ័យសុខភាពទាំងនេះ។ ហេតុដូច្នេះហើយ អ្នកចាំបាច់ត្រូវទទួលបានការថែទាំសុខភាពជាប្រចាំ ដើម្បីរក្សាសុខភាព និងសុខុមាលភាពរបស់អ្នក។



## តើមានហេតុផលអ្វីផ្សេងទៀតដែលអាចនាំឱ្យមានការបដិសេធទិដ្ឋាការសម្រាប់អ្នកដែលមានជំងឺរលាកថ្លើមប្រភេទ B?

ប្រសិនបើអ្នកដាក់ពាក្យសុំទិដ្ឋាការដែលមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃវិវត្តទៅជាជំងឺថ្លើមដំណាក់កាលចុងក្រោយ ហើយទំនងជាត្រូវការការបន្សាំថ្លើមនោះ ពាក្យសុំទិដ្ឋាការរបស់ពួកគេអាចលើសពី 'កម្រិតចំណាយប្រាក់ដ៏ច្រើន'។ លើសពីនេះទៀត វាបង្កើនការព្រួយបារម្ភអំពីការទទួលបានសមធម៌នូវធនធានវេជ្ជសាស្ត្រដែលមានកម្រិត ដូចជាការបន្សាំថ្លើមពីអ្នកបរិច្ចាគដែលបានចែកឋានទៅ ដែលអាចប៉ះពាល់ដល់ការរង់ចាំការបរិច្ចាគសរីរាង្គសម្រាប់អ្នកជំងឺនៅប្រទេសអូស្ត្រាលី។

សម្រាប់ព័ត៌មានច្រើនទៀត សូមចូលមើល Hepatitis B and Immigration នៅ ashm.org.au

## ? ខ្ញុំមិនមានជំងឺរលាកថ្លើមប្រភេទ B ទេ ប៉ុន្តែសមាជិកគ្រួសារ ឬអ្នករស់នៅក្នុងបន្ទុករបស់ខ្ញុំមាន។ តើវានឹងប៉ះពាល់ដល់ការដាក់ពាក្យសុំទិដ្ឋាការរបស់យើងដែរឬទេ?

មនុស្សទាំងអស់ដែលបានដាក់បញ្ចូលនៅក្នុងពាក្យសុំទិដ្ឋាការត្រូវតែបំពេញទៅតាមលក្ខខណ្ឌតម្រូវសុខភាពដែលពាក់ព័ន្ធ។ ក្នុងករណីខ្លះ ក្រសួងក៏អាចស្នើសុំសមាជិកគ្រួសារដែលមិនធ្វើចំណាកស្រុកឱ្យទៅពិនិត្យសុខភាព និងបំពេញតាមលក្ខខណ្ឌសុខភាពដែលពាក់ព័ន្ធផងដែរ។ ទោះបីជា វារឿងមិនកើតឡើងញឹកញាប់ដែលក្រសួងស្នើសុំសមាជិកគ្រួសារដែលមិនធ្វើចំណាកស្រុកឱ្យពិនិត្យសុខភាព អ្នកគួរតែស្វែងរកដំបូន្មានអំពីផលប៉ះពាល់ណាមួយដែលអាចមានលើពាក្យសុំទិដ្ឋាការរបស់អ្នក។ ប្រសិនបើសមាជិកម្នាក់នៃក្រុមគ្រួសារមិនបំពេញតាមលក្ខខណ្ឌតម្រូវសុខភាពទេ ក្រសួងនឹងបដិសេធពាក្យសុំទិដ្ឋាការនោះ។ គោលការណ៍នេះហៅថា **"ធ្លាក់មួយ ធ្លាក់ទាំងអស់"**។

ដូចបានលើកឡើងខាងលើ សមាជិកគ្រួសារម្នាក់ដែលរស់នៅមានជំងឺរលាកថ្លើមប្រភេទ B អាចនឹងមិនមានបញ្ហាក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវសុខភាពដោយសារតែស្ថានភាពជំងឺរលាកថ្លើមប្រភេទ B របស់ពួកគេតែមួយនោះទេ។ ទោះជាយ៉ាងណាក៏ដោយ លក្ខខណ្ឌតម្រូវសុខភាពសម្រាប់ទិដ្ឋាការនីមួយៗអាចពិចារណាលើលក្ខខណ្ឌសុខភាពជាច្រើនផ្សេងទៀត ដែលពាក់ព័ន្ធនឹងការវាយតម្លៃរបស់ខ្លួន។ **(សម្រាប់ព័ត៌មានបន្ថែមអំពីជំងឺរលាកថ្លើមប្រភេទ B និងលក្ខខណ្ឌតម្រូវសុខភាព សូមមើលខាងលើ)។**

## ? ខ្ញុំមានជំងឺរលាកថ្លើមប្រភេទ B ហើយខ្ញុំកំពុងមានគម្រោងទៅសិក្សានៅប្រទេសអូស្ត្រាលី។ តើរឿងនេះនឹងប៉ះពាល់ដល់ការដាក់ពាក្យសុំទិដ្ឋាការរបស់ខ្ញុំដែរឬទេ?

ជាទូទៅ អ្នកដាក់ពាក្យសុំទិដ្ឋាការដែលមានជំងឺរលាកថ្លើមប្រភេទ B នឹងមិនទទួលបានការបដិសេធទិដ្ឋាការដោយសារតែជំងឺរលាកថ្លើមប្រភេទ B របស់ពួកគេនោះទេ។

ទោះជាយ៉ាងណាក៏ដោយ អ្នកដាក់ពាក្យសុំដែលមានបំណងសិក្សាដើម្បីក្លាយជាបុគ្គលិកថែមទាំសុខភាពដែលអនុវត្តនីតិវិធីពេលមានការប៉ះពាល់អាចកើតឡើង (វេជ្ជបណ្ឌិត គិលានុបដ្ឋាក ទន្តបណ្ឌិត គ្រូពេទ្យសង្គ្រោះបន្ទាន់) អាចតម្រូវឱ្យធ្វើការពិនិត្យសុខភាពបន្ថែម និង/ឬផ្តល់ព័ត៌មានបន្ថែមដល់ក្រសួងមហាផ្ទៃ។ ក្រសួងអាច ស្នើសុំអ្នកឱ្យផ្តល់ឯកសារបន្ថែមពីនិយោជកឬស្ថាប័នអប់រំរបស់អ្នក ដែលបញ្ជាក់ថាអ្នកនឹងមិនអនុវត្តនីតិវិធីពេលមានការប៉ះពាល់អាចកើតឡើងនោះទេ។

ដរាបណាអ្នកអនុវត្តតាមលក្ខខណ្ឌតម្រូវនៃ **គោលការណ៍ណែនាំថ្នាក់ជាតិអូស្ត្រាលី** នោះអ្នកមិនត្រូវបានគេរារាំងពីការបន្តការសិក្សា ឬបម្រើការជាបុគ្គលិកថែទាំសុខភាពនៅក្នុងប្រទេសអូស្ត្រាលីទេ ទោះបីជាអ្នកមានជំងឺរលាកថ្លើមប្រភេទ B ក៏ដោយ។ ក្រសួងណែនាំយ៉ាងម៉ឺងម៉ាត់ថា អ្នកដាក់ពាក្យសុំទិដ្ឋាការនៅក្នុងកាលៈទេសៈទាំងនេះគួរស្វែងរកការពិគ្រោះយោបល់ពីភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះបញ្ជីស្របច្បាប់ ឬមេធាវីដែលមានបទពិសោធន៍លើកិច្ចការទិដ្ឋាការដែលពាក់ព័ន្ធនឹងសុខភាព។

សម្រាប់ព័ត៌មានច្រើនទៀត សូមចូលមើល CDNA National Guidelines នៅ health.gov.au

# អំពីការពិនិត្យសុខភាព

ក្រសួងនឹងតម្រូវឱ្យអ្នកដាក់ពាក្យសុំទិដ្ឋាការអចិន្ត្រៃយ៍ទាំងអស់ និងអ្នកដាក់ពាក្យសុំទិដ្ឋាការបណ្តោះអាសន្នមួយចំនួនឱ្យពិនិត្យសុខភាពសម្រាប់ការដាក់ពាក្យសុំទិដ្ឋាការរបស់ពួកគេ។ ការធ្វើតេស្តពិនិត្យសុខភាពជាក់លាក់ដែលតម្រូវឱ្យធ្វើ អាស្រ័យលើកត្តាផ្សេងៗរួមទាំងប្រភេទទិដ្ឋាការដែលបានស្នើសុំ (ឧទាហរណ៍ ការងារដែលអ្នកដាក់ពាក្យសុំមានបំណងចង់ធ្វើ ឬការសិក្សាដែលអ្នកដាក់ពាក្យសុំមានបំណងចង់រៀន) រយៈពេលនៃទិដ្ឋាការ ប្រទេសដែលអ្នកដាក់ពាក្យសុំធ្វើចំណាកស្រុក អាយុរបស់អ្នកដាក់ពាក្យសុំ និងព័ត៌មានដែលអ្នកបានផ្តល់ឱ្យទៅក្រសួងមហាផ្ទៃនៅក្នុងពាក្យសុំទិដ្ឋាការ។ ការពិនិត្យសុខភាពអាចរួមមាន៖



**ការធ្វើតេស្តទឹកនោម**



**ការពិនិត្យសម្ពាធឈាម**



**ការធ្វើតេស្តឈាម (ការធ្វើតេស្តពិនិត្យជំងឺរបេង ការធ្វើតេស្តមេរោគអេដស៍ ការធ្វើតេស្តជំងឺរលាកថ្លើមប្រភេទ B និង C និងការធ្វើតេស្តរោគស្វាយ)**



**ការពិនិត្យភ្នែក - អានអក្សរពីតារាង**



**ទម្ងន់ និងកម្ពស់- ដើម្បីកំណត់សន្ទស្សន៍ម៉ាសរាងកាយរបស់អ្នក (BMI)**



**ការពិនិត្យបេះដូង**



**ការពិនិត្យវេផ្លិច - នៅលើជើង**



**ត្រចៀក និងបំពង់ក**



**ដុំពកនៅក្រោមក្លៀក និងក្បាលពោះ**



**ការថតសួតដោយប្រើកាំរស្មីអ៊ិច**

សម្រាប់ព័ត៌មានច្រើនទៀត សូមចូលមើល What health examinations you need នៅ immi.homeaffairs.gov.au

# ការពិនិត្យសុខភាព - សំណួរដែលគេសួរញឹកញាប់

## តើទិដ្ឋាការទេសចរណ៍តម្រូវឱ្យមានការពិនិត្យសុខភាពដែរឬទេ?

ជាទូទៅ ក្រសួងមិនតម្រូវឱ្យមានការពិនិត្យសុខភាពទេ សម្រាប់ទិដ្ឋាការស្នាក់នៅបណ្តោះអាសន្នរយៈពេលខ្លីទេ ដូចជាទិដ្ឋាការទេសចរណ៍។ មានករណីមួយចំនួនដែលតម្រូវឱ្យមានការពិនិត្យសុខភាព ឧទាហរណ៍ ប្រសិនបើអ្នកមានអាយុលើសពី 75 ឆ្នាំ ឬប្រសិនបើអ្នកមានបំណងស្នាក់នៅក្នុងប្រទេសអូស្ត្រាលីរយៈពេលពី 6 ទៅ 12 ខែ។

ការពិនិត្យសុខភាព និងប្រភេទនៃការធ្វើតេស្តដែលតម្រូវឱ្យពិនិត្យគឺអាស្រ័យលើប្រភេទ និងរយៈពេលទិដ្ឋាការ ប្រទេសដើមកំណើត អាយុរបស់អ្នក និងព័ត៌មានលម្អិតនៅក្នុងពាក្យសុំទិដ្ឋាការរបស់អ្នក។ ក្រសួងនឹងជូនដំណឹងមកអ្នក ប្រសិនបើក្រសួងតម្រូវឱ្យអ្នកពិនិត្យសុខភាព បន្ទាប់ពីអ្នកបានដាក់ពាក្យសុំទិដ្ឋាការរបស់អ្នក។

## តើខ្ញុំគួរបង្ហាញស្ថានភាពជំងឺរលាកថ្លើមប្រភេទ B របស់ខ្ញុំ ក្នុងអំឡុងពេលដំណើរការដាក់ពាក្យសុំទិដ្ឋាការដែរឬទេ?

វាជារឿងសំខាន់សម្រាប់អ្នកដាក់ពាក្យត្រូវឆ្លើយសំណួរណាមួយដោយស្មោះត្រង់ ក្នុងអំឡុងពេលដំណើរការដាក់ពាក្យសុំទិដ្ឋាការ ហើយមិនត្រូវផ្តល់ព័ត៌មានបំភាន់ ឬព័ត៌មានមិនពិតដល់ក្រសួងទេ។ សំណួរមួយចំនួនអាចសួរអ្នកដោយផ្ទាល់ អំពីស្ថានភាពសុខភាពណាមួយដែលអ្នកកំពុងរស់នៅជាមួយ ខណៈសំណួរផ្សេងទៀតអាចសួរអំពីសេវាថែទាំសុខភាពណាមួយដែលអ្នកមានបំណងចង់ប្រើប្រាស់ នៅពេលស្នាក់នៅប្រទេសអូស្ត្រាលីដែលទាក់ទងនឹងស្ថានភាពសុខភាព។ មុនពេលដាក់ពាក្យសុំទិដ្ឋាការ អ្នកគួរតែស្វែងរកដំបូន្មានពីភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះបញ្ជីស្របច្បាប់ ឬមេធាវី។ ក្រសួងណែនាំថាបុគ្គលដែលរស់នៅមានជំងឺរលាកថ្លើមប្រភេទ B គួរតែពិភាក្សាឬបង្ហាញស្ថានភាពរបស់ពួកគេ និងព័ត៌មានសំខាន់ៗផ្សេងទៀតប្រាប់មេធាវី ឬភ្នាក់ងារអន្តោប្រវេសន៍របស់ពួកគេ ដើម្បីឱ្យពួកគេអាចផ្តល់ដំបូន្មានបានត្រឹមត្រូវ។

សម្រាប់ព័ត៌មានច្រើនទៀត សូមចូលមើល Who do you have to tell? នៅ hepatitisaustralia.com

## តើខ្ញុំអាចពិនិត្យសុខភាពនៅឯណា?

ការពិនិត្យសុខភាពសម្រាប់ការតាំងលំនៅបណ្តោះអាសន្ន និងអចិន្ត្រៃយ៍នៅអូស្ត្រាលីអាចធ្វើបាននៅក្នុងប្រទេសអូស្ត្រាលី ឬនៅតាមទីតាំងដែលបានអនុម័តនៅក្នុងប្រទេសផ្សេងទៀត។ ប្រសិនបើអ្នកដាក់ពាក្យសុំទិដ្ឋាការរស់នៅក្នុងប្រទេសអូស្ត្រាលី អ្នកត្រូវធ្វើតេស្តតាមរយៈអ្នកផ្តល់សេវាពិនិត្យសុខភាពទាក់ទងនឹងអន្តោប្រវេសន៍ដែលមានការអនុញ្ញាតត្រឹមត្រូវ (បច្ចុប្បន្ន អ្នកផ្តល់សេវាដែលមានការអនុញ្ញាតត្រឹមត្រូវគឺ Bupa Medical Visa Services)។ ប្រសិនបើអ្នកដាក់ពាក្យសុំទិដ្ឋាការត្រូវពិនិត្យសុខភាពនៅក្រៅប្រទេសអូស្ត្រាលី ក្រសួងតម្រូវឱ្យអ្នកទៅពិនិត្យសុខភាពជាមួយក្រុមគ្រូពេទ្យ ឬគ្លីនិកដែលក្រសួងមហាផ្ទៃបានអនុម័ត នៅតាមទីតាំងដែលបានអនុម័តនៅក្រៅប្រទេសអូស្ត្រាលី។

សម្រាប់ព័ត៌មានច្រើនទៀត សូមចូលមើល Meeting our health requirement នៅ immi.homeaffairs.gov.au

## តើខ្ញុំគួរដឹងអ្វីខ្លះដែរនៅពេលដាក់ពាក្យសុំទិដ្ឋាការថ្មីនៅប្រទេសអូស្ត្រាលី ប្រសិនបើខ្ញុំមានផ្ទៃពោះ ហើយមានជំងឺរលាកថ្លើមប្រភេទ B?

ប្រសិនបើអ្នកមានទិដ្ឋាការស្នាក់នៅក្នុងប្រទេសអូស្ត្រាលី អ្នកអាចប្រើប្រាស់ការថែទាំសុខភាពសម្រាប់ខ្លួនអ្នក និងកូនរបស់អ្នកអំឡុងពេលមានផ្ទៃពោះ សម្រាលកូន និងក្រោយសម្រាលកូន។ ទោះជាយ៉ាងណាក៏ដោយ ការចំណាយប្រាក់អាស្រ័យលើប្រភេទទិដ្ឋាការរបស់អ្នក និងការធានារ៉ាប់រងសុខភាពឯកជនរបស់អ្នក។

ប្រសិនបើអ្នកមានជំងឺរលាកថ្លើមប្រភេទ B ហើយមានផ្ទៃពោះ វាជារឿងសំខាន់ដែលអ្នកត្រូវតែទៅជួបវេជ្ជបណ្ឌិត ដើម្បីតាមដានសុខភាពថ្លើម បន្ទុកវីរុស និងវាយតម្លៃថាតើអ្នកត្រូវការការព្យាបាលដែរឬទេ។ ការពិភាក្សាអំពីស្ថានភាពសុខភាពរបស់អ្នកជាមួយឆ្មប ឬវេជ្ជបណ្ឌិតរបស់អ្នកនឹងជួយគ្រប់គ្រងជំងឺរលាកថ្លើមប្រភេទ B និងធានាថាអ្នក និងកូនរបស់អ្នកមានសុខភាពល្អ។

ក្រសួងបានណែនាំយ៉ាងម៉ឺងម៉ាត់ថា អ្នកដាក់ពាក្យសុំទិដ្ឋាការដែលស្ថិតក្នុងកាលៈទេសៈទាំងនេះគួរស្វែងរកការពិគ្រោះយោបល់ពីភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះបញ្ជីស្របច្បាប់ឬមេធាវី ដើម្បីពិភាក្សាអំពី ស្ថានភាពរបស់ពួកគេមុនពេលដាក់ពាក្យសុំ ព្រោះក្រសួងអាចតម្រូវឱ្យអ្នកដាក់ពាក្យសុំទិដ្ឋាការ ឬអ្នកនៅក្នុងបន្ទុកចុះហត្ថលេខាលើកិច្ចសន្យាពិនិត្យសុខភាពគភ៌ប្រសិនបើត្រូវការការពិនិត្យសុខភាព។

សម្រាប់ព័ត៌មានច្រើនទៀត សូមចូលមើល Hepatitis B, Pregnancy and Babies, Pregnancy Health Undertaking, Me, my baby and hepatitis B នៅ svhm.org.au

# ឱសថ - សំណួរដែលគេសួរញឹកញាប់

## តើខ្ញុំអាចយកថ្នាំព្យាបាលជំងឺរលាកថ្លើមប្រភេទ B របស់ខ្ញុំទប្រទេសអូស្ត្រាលីបានទេ? តើមន្ត្រីអន្តោប្រវេសន៍នឹងឃាត់ខ្ញុំទេ ប្រសិនបើពួកគេរកឃើញថ្នាំរបស់ខ្ញុំ?

ប្រទេសអូស្ត្រាលីមានបទប្បញ្ញត្តិដ៏តឹងរ៉ឹងទាក់ទងនឹងការនាំចូលឱសថ(ថ្នាំ) ដូច្នេះវាជារឿងចាំបាច់ត្រូវយល់ដឹងអំពីបទប្បញ្ញត្តិនានាដើម្បីជៀសវាងបញ្ហាណាមួយនៅកន្លែងអន្តោប្រវេសន៍។ មន្ត្រីគយនឹងមិនរារាំងអ្នកពីការនាំយកឱសថ ព្យាបាលជំងឺរលាកថ្លើមប្រភេទ B របស់អ្នកមកប្រទេសអូស្ត្រាលីទេ ប្រសិនបើវាស្របទៅតាមគោលការណ៍ណែនាំរបស់រដ្ឋបាលគ្រប់គ្រងលើទំនិញសម្រាប់ការព្យាបាលអូស្ត្រាលី (Australian Therapeutic Goods Administration-TGA) ហើយអ្នកប្រកាសត្រឹមត្រូវនៅពេលមកដល់ប្រទេសអូស្ត្រាលី។

វាជារឿងសំខាន់ណាស់ដែលអ្នកចាំបាច់ត្រូវមានវេជ្ជបញ្ជាត្រឹមត្រូវសម្រាប់ថ្នាំរបស់អ្នក។ វេជ្ជបញ្ជារបស់អ្នកត្រូវតែសរសេរជាភាសាអង់គ្លេស ហើយមានព័ត៌មានលម្អិតដូចជាឈ្មោះរបស់អ្នក ឈ្មោះថ្នាំ (ឧទារណ៍ Entecavir ឬ Tenofovir) ការណែនាំអំពីចំនួនដែលត្រូវប្រើនិងព័ត៌មានពីវេជ្ជបណ្ឌិតរបស់អ្នក។ លើសពីនេះការមានសំបុត្របញ្ជាក់ពីវេជ្ជបណ្ឌិតរបស់អ្នកដែលពន្យល់ពីភាពចាំបាច់នៃថ្នាំដែលអ្នកត្រូវការអាចជួយជាប្រយោជន៍ពេលឆ្លងកាត់មន្ត្រីគយអន្តោប្រវេសន៍។ សំបុត្របញ្ជាក់ពីវេជ្ជបណ្ឌិតរបស់អ្នកគួរតែដាក់បញ្ចូលព័ត៌មានលម្អិតអំពីស្ថានភាពរបស់អ្នក ភាពចាំបាច់នៃថ្នាំដែលអ្នកត្រូវការ និងចំនួនដូសថ្នាំតាមវេជ្ជបញ្ជា។ ម៉្យាងទៀត ប្រសិនបើថ្នាំនោះមិននៅក្នុងមានការរឹតត្បិតនៅក្នុងប្រទេសអូស្ត្រាលីទេ អ្នកអាចយកំចូលថ្នាំមកពីក្រៅប្រទេសសម្រាប់ការផ្គត់ផ្គង់អតិបរមារយៈពេល 3 ខែបាន។

សម្រាប់ព័ត៌មានច្រើនទៀត សូមចូលមើល Entering Australia នៅ tga.gov.au

## តើខ្ញុំអាចទិញថ្នាំព្យាបាលជំងឺរលាកថ្លើមប្រភេទ B នៅប្រទេសអូស្ត្រាលី ដោយប្រើវេជ្ជបញ្ជាពីបរទេសបានដែរឬទេ?

អ្នកមិនអាចប្រើវេជ្ជបញ្ជាដែលផ្តល់ដោយគ្រូពេទ្យពីប្រទេសរបស់អ្នកដើម្បីទិញថ្នាំនៅក្នុងប្រទេសអូស្ត្រាលីបានទេ។ ប្រសិនបើអ្នកប្រើអស់ថ្នាំព្យាបាលជំងឺរលាកថ្លើមប្រភេទ B (ឧទាហរណ៍ entecavir ឬ tenofovir) ឬត្រូវការថ្នាំក្នុងអំឡុងពេលស្នាក់នៅក្នុងប្រទេសអូស្ត្រាលី អ្នកអាចទៅជួបវេជ្ជបណ្ឌិតផ្នែកជំងឺទូទៅក្នុងប្រទេសអូស្ត្រាលី (ដែលគេស្គាល់ថាជាអ្នកចេញវេជ្ជបញ្ជាតាមផ្នែកទី s100) ឬគ្រូពេទ្យឯកទេស ដើម្បីទទួលបានវេជ្ជបញ្ជាអូស្ត្រាលីដែលមានសុពលភាព។ អ្នកអាចប្រើវេជ្ជបញ្ជានោះដើម្បីទិញថ្នាំពីឱសថស្ថាននៅប្រទេសអូស្ត្រាលី។

**សម្រាប់ព័ត៌មានច្រើនទៀត សូមចូលមើល** Travelling to or from Australia with medicines and medical devices, Personal Importation Scheme **នៅ odc.gov.au**

**ដើម្បីស្វែងរកអ្នកចេញវេជ្ជបញ្ជា S100 សូមចូលទៅកាន់**កម្មវិធីអ្នកចេញវេជ្ជបញ្ជា **នៅ ashm.org.au**

**បន្ទាប់ពីបានមកដល់ប្រទេសអូស្ត្រាលី ដើម្បីគ្រប់គ្រងការថែទាំជំងឺរលាកថ្លើមប្រភេទ B របស់អ្នក អ្នកគួរតែ៖**

- ស្វែងរកអ្នកផ្តល់សេវាថែទាំសុខភាពក្នុងមូលដ្ឋានដែលអាចជួយគ្រប់គ្រងជំងឺរលាកថ្លើមប្រភេទ B របស់អ្នក និងតាមដានសុខភាពរបស់អ្នក។ នៅប្រទេសអូស្ត្រាលីវេជ្ជបណ្ឌិតព្យាបាលជំងឺទូទៅ (GP) ឬគ្រូពេទ្យឯកទេសអាចមើលថែទាំជំងឺរលាកថ្លើមប្រភេទ B បាន។
- កំណត់ពេលណាត់ជួបជាទៀងទាត់សម្រាប់ការពិនិត្យជំងឺរលាកថ្លើមប្រភេទ B រួមទាំងការធ្វើតេស្តឈាម ការធ្វើតេស្តមុខងារថ្លើម និងអ៊ុលត្រាសោន ប្រសិនបើចាំបាច់ទៅតាមការណែនាំរបស់វេជ្ជបណ្ឌិត។
- ប្រសិនបើអ្នកកំពុងទទួលការព្យាបាលនៅពេលបច្ចុប្បន្ននេះ សូមកុំផ្អាក ឬបញ្ឈប់ការប្រើថ្នាំជំងឺរលាកថ្លើមប្រភេទ B របស់អ្នក លុះត្រាតែអ្នកទទួលបានការណែនាំពីវេជ្ជបណ្ឌិតថែទាំសុខភាពរបស់អ្នក។
- អ្នកអាចទាក់ទងទៅក្រុមគាំទ្រ ឬអង្គការសហគមន៍នៅតាមមូលដ្ឋាន ប្រសិនបើត្រូវការជំនួយបន្ថែម រួមមានអង្គការ LiverWELL, Hepatitis B Voices Australia និងអង្គការផ្សេងទៀត។

**សម្រាប់ព័ត៌មានច្រើនទៀត សូមចូលមើល**
LiverWELL **នៅ liverwell.org.au**
Hepatitis B Voices Australia **នៅ hepbvoices.au**
HepBCommunity.org **នៅ hepbcommunity.org**



# ការធ្វើការនៅប្រទេសអូស្ត្រាលី - សំណួរដែលគេសួរញឹកញាប់

## តើខ្ញុំត្រូវបង្ហាញប្រាប់និយោជករបស់ខ្ញុំអំពីស្ថានភាពជំងឺរលាកថ្លើមប្រភេទ B របស់ខ្ញុំដែរឬទេ?

សម្រាប់ការងារភាគច្រើន អ្នកមិនចាំបាច់បង្ហាញប្រាប់និយោជក ឬមិត្តរួមការងារអ្នកថា អ្នកមានជំងឺរលាកថ្លើមប្រភេទ B នោះទេ។ យ៉ាងណាក៏ដោយមានប្រភេទការងារមួយចំនួនតូច ដែលតម្រូវឱ្យអ្នកបង្ហាញប្រាប់ពីស្ថានភាពសុខភាពរបស់អ្នក ឬធ្វើតេស្តឈាម។ ទាំងនេះរួមមាន៖

- ប្រសិនបើអ្នកជាបុគ្គលិកថែទាំសុខភាពដែលការងារអាចនិងនីតិវិធីពេលមានការប៉ះពាល់អាចកើតឡើង(EPPs)។
- ប្រសិនបើអ្នកធ្វើការឬគ្រោងនឹងដាក់ពាក្យសុំចូលបម្រើក្នុងកងកម្លាំងយោធាការពារប្រទេសអូស្ត្រាលី។

ការងារមួយចំនួនក៏អាចតម្រូវឱ្យអ្នកបញ្ជាក់ថាអ្នកបានចាក់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ B ផងដែរ។ ប្រសិនបើអ្នកមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ អ្នកគួរតែពិគ្រោះជាមួយវេជ្ជបណ្ឌិតទាក់ទងនឹងលក្ខខណ្ឌតម្រូវនេះ។ វេជ្ជបណ្ឌិតអាចសរសេរលិខិតបញ្ជាទៅនិយោជករបស់អ្នកដើម្បីពន្យល់ពីហានិភ័យតិចតួចដែលទាក់ទងនឹងស្ថានភាពរបស់អ្នក និងបញ្ជាក់ពីភាពសមស្របរបស់អ្នកសម្រាប់ការងារ។

ប្រសិនបើនិយោជកបដិសេធការងាររបស់អ្នក ឬបណ្តេញអ្នកចេញពីការងារ ដោយសារតែស្ថានភាពជំងឺរលាកថ្លើមប្រភេទ B របស់អ្នក អ្នកគួរតែស្វែងរកការពិគ្រោះយោបល់ផ្នែកច្បាប់ ឬពិចារណាការដាក់ពាក្យបណ្តឹងរឹតវ៉ាទៅគណៈកម្មការសិទ្ធិមនុស្សអូស្ត្រាលី (AHRC)។ AHRC ផ្តល់ជំនួយក្នុងដំណើរការបណ្តឹងតវ៉ាដោយឥតគិតថ្លៃ ដែលមិនតម្រូវឱ្យមានតំណាងផ្នែកច្បាប់ ហើយអាចដាក់បញ្ចូលការសម្របសម្រួលជាផ្នែកនៃដំណើរការដោះស្រាយ។

**សម្រាប់ព័ត៌មានច្រើនទៀត សូមចូលមើល** Know your rights **នៅ liverwell.org.au ឬ** Your rights and responsibilities **នៅ hepatitisaustralia.com.**

**ដើម្បីដាក់ពាក្យបណ្តឹង សូមចូលទៅកាន់**ដំណើរការបណ្តឹងសម្រាប់ការតវ៉ាអំពីភេទ ពូជសាសន៍ ពិការភាព និងការរើសអើងអាយុ**នៅ humanrights.gov.au**



## ខ្ញុំជាបុគ្គលិកថែទាំសុខភាពដែលរស់នៅមានជំងឺរលាកថ្លើមប្រភេទ B។ តើខ្ញុំអាចអនុវត្តនីតិវិធីពេលមានការប៉ះពាល់អាចកើតឡើង (EPPs) បានទេ?

បុគ្គលិកថែទាំសុខភាពដែលមានជំងឺរលាកថ្លើមប្រភេទ B ត្រូវផ្តល់ព័ត៌មានបន្ថែមទៅក្រសួងមហាផ្ទៃ ប្រសិនបើមានបំណងទៅធ្វើការនៅប្រទេសអូស្ត្រាលី។ វាជារឿងសំខាន់ដែលត្រូវដឹងថាមេរោគរលាកថ្លើមប្រភេទ B តែម្យ៉ាងមិនអាចដកសិទ្ធិនរណាម្នាក់មិនឱ្យធ្វើការជាបុគ្គលិកថែទាំសុខភាព ឬមិនឱ្យធ្វើការក្នុងតួនាទីដែលពួកគេអនុវត្តនីតិវិធីពេលមានការប៉ះពាល់អាចកើតឡើង (EPPs) នោះទេ។ ទោះយ៉ាងណាក៏ដោយ និយោជកត្រូវតែអនុវត្តតាមគោលការណ៍ណែនាំស្តីពីបណ្តាញជំងឺឆ្លងអូស្ត្រាលី (Communicable Diseases Network Australia, CDNA)។ បច្ចុប្បន្ន បុគ្គលិកថែទាំសុខភាពដែលមានជំងឺរលាកថ្លើមប្រភេទ B ទទួលបានការអនុញ្ញាតឱ្យអនុវត្ត EPP ប្រសិនបើចំនួនមេរោគរបស់ពួកគេក្រោម 200 ឯកតាក្នុងមួយមីលីលីត្រ (200 IU/mL) ហើយពួកគេបំពេញតាមលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងគោលនយោបាយ និងគោលការណ៍ណែនាំដែលពាក់ព័ន្ធ។

**សម្រាប់ព័ត៌មានច្រើនទៀត សូមចូលមើល CDNA National Guidelines នៅ health.gov.au**

# ជំបូន្មានផ្នែកច្បាប់

ដើម្បីទទួលបានការណែនាំពីអ្នកឯកទេស អ្នកដែលមានជំងឺរលាកថ្លើមប្រភេទ B អាចទាក់ទងអង្គការ HALC ដើម្បីទទួលបានព័ត៌មាន ឬការណែនាំអំពីបញ្ហាផ្លូវច្បាប់ទាក់ទងនឹងជំងឺរលាកថ្លើមប្រភេទ B រួមទាំងព័ត៌មានអន្តោប្រវេសន៍ផងដែរ។ អង្គការ HALC គឺជាមជ្ឈមណ្ឌលច្បាប់សហគមន៍ដែលមានទីតាំងនៅរដ្ឋញូវសៅវែល ដែលអាចផ្តល់សេវាកម្មផ្នែកច្បាប់ដោយឥតគិតថ្លៃដល់អ្នកមានបញ្ហាសុខភាពនានា ដូចជាជំងឺរលាកថ្លើមប្រភេទ B ជាដើម។

**អ៊ីមែល៖ halc@halc.org.au**
**ទូរសព្ទ៖ (02) 9492 6540**
**សម្រាប់ព័ត៌មានច្រើនទៀត សូមចូលមើល នៅ HALC នៅ halc.org.au**







## ឯកសារយោង

**1.** Australian Government Department of Defence. Organisation Structure. Accessed July, 2024. https://www.defence.gov.au/about/who-we-are/organisation-structure **2.** Bupa Medical Visa Services. Need a Visa Medical Assessment? You're in the right place. Accessed July, 2024. https://www.bupa.com.au/bupamvs **3.** Australian Government Department of Home Affairs. Who we are. Accessed July, 2024. https://www.homeaffairs.gov.au/about-us/who-we-are/ **4.** Think Visa. Dependent Visa Australia. Updated April 11, 2024. Accessed July, 2024. https://www.thinkvisa.com.au/australia-immigration-trends/dependent-visa-australia#:~:text=A%20Dependent%20Visa%20Australia%20is%20a%20visa%20ca tegory%20that%20enables,on%20the%20primary%20visa%20holder. **5.** Communicable Diseases Network Australia. Guidance on classification of exposure-prone and non-exposure-prone procedures in Australia 2017. Updated March, 2020. Accessed July 2024. https://www.health.gov.au/sites/default/files/documents/2020/03/cdna-guidance-on-classification-of-exposure-prone-and-non-exposure-prone-procedures-in-australia-2017.pdf **6.** Mohanty A, Kabi A, & Mohanty AP. Health problems in healthcare workers: A review. Journal of family medicine and primary care, 2019;8(8), 2568–2572. Accessed July, 2024. https://doi.org/10.4103/jfmpc.jfmpc_431_19 **7.** LiverWELL. What is hepatitis B? Updated October, 2024. Accessed January, 2025. https://liverwell.org.au/liver-conditions/hepatitis-b/what-is-hepatitis-b/ **8.** Hepatitis B Voices Australia. About Us. Updated 2022. Accessed July, 2024. https://www.hepbvoices.au/about-us **9.** Wikipedia. ជំបូន្មានផ្នែកច្បាប់ Updated August, 2024. Accessed January, 2025. https://en.wikipedia.org/wiki/Legal_advice **10.** Community Legal Centres Australia. ជំបូន្មានផ្នែកច្បាប់ Updated 2022. Accessed July, 2024. https://clcs.org.au/services/data/discrete-services/legal-advice/#:~:text=Definition,an%20organisation%20or%20a%20group. **11.** Johns Hopkins Medicine. Liver Transplant. Accessed July 2025. https://www.hopkinsmedicine.org/health/treatment-tests-and-therapies/liver-transplant **12.** LiverWELL. About Us. Updated Octorber, 2024. Accessed January, 2025. https://liverwell.org.au/about-us/organisation/ **13.** Australian Health Practitioner Regulation Agency and the National Boards. Register of practitioners. Accessed July, 2024. https://www.ahpra.gov.au/registration/registers-of-practitioners.aspx#:~:text=Protected%20titles%20and%20specialist%20titles,and%20professional%20standards%20of%20practice. **14.** Australian Government Department of Home Affairs. Permanent Resident. Updated December 4, 2024. Accessed January, 2025. https://immi.homeaffairs.gov.au/visas/permanent-resident#:~:text=%E2%80%8BYou%20can%20become%20a,to%20become%20an%20Australian%20citizen **15.** Australian Government Department of Health, Disability and Ageing. About private health insurance. Updated March 13, 2025. Accessed 2025. https://www.health.gov.au/topics/private-health-insurance/about-private-health-insurance **16.** Australian Government Department of Health, Disability and Ageing. About prescription. Updated March 5, 2024. Accessed July, 2024. https://www.health.gov.au/topics/medicines/about-prescriptions **17.** ASHM Health. PrescriberProgram. Accessed July 2024, https://ashm.org.au/prescriber-programs/ **18.** Australian Government Department of Home Affairs. Temporary Activity Visa. Updated September 23, 2024. Accessed January 2025. https://immi.homeaffairs.gov.au/visas/getting-a-visa/visa-listing/temporary-activity-408 **19.** Hepatitis Australia. Monitoring hepatitis B. Updated 2022. Accessed July, 2024. https://www.hepatitisaustralia.com/monitoring-hepatitis-b

## ប្រវត្តិនៃការពិនិត្យឡើងវិញ

ពិនិត្យឡើងវិញចុងក្រោយ៖ ខែមករា ឆ្នាំ 2025

ផលិតដោយ៖ Tepy Hoeung និង Alain Palines

ពិនិត្យឡើងវិញដោយ៖ សាស្ត្រាចារ្យ Benjamin Cowie, សាស្ត្រាចារ្យរង David Carter, Jennifer MacLachlan, Mielle Abbott , Rhys Evans, Hepatitis B Voices Australia.

យើងសូមថ្លែងអំណរគុណចំពោះបុគ្គលដែលមានបទពិសោធទាំងអស់ដែលបានលះបង់ពេលវេលា និងការយល់ដឹងស៊ីជម្រៅរបស់ពួកគេក្នុងការពិនិត្យឡើងវិញលើឯកសារនេះ និងការផ្តល់នូវមតិកែលម្អដែលមិនអាចកាត់ថ្លៃបាន។

# សំណួរដែលគេសួរញឹកញាប់អំពីទិដ្ឋាការ និងអន្តោប្រវេសន៍ទាក់ទងនឹងជំងឺរលាកថ្លើមប្រភេទ B



HEPLINK AUSTRALIA

HepLink Australia ផ្តល់ព័ត៌មានអំពីជំងឺរលាកថ្លើមដោយមេរោគ ដំបូន្មាន និងសេវាកម្មគាំទ្រដល់នរណាម្នាក់ដោយឥតគិតថ្លៃ និងសម្ងាត់ នៅគ្រប់ទីកន្លែងក្នុងប្រទេសអូស្ត្រាលី។ HepLink ត្រូវបានផ្តល់មូលនិធិដោយរដ្ឋាភិបាលអូស្ត្រាលី។

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ សូមហៅទូរសព្ទទៅ TIS National តាមលេខ 131 450 ហើយសុំឱ្យពួកគេហៅទូរសព្ទទៅ HepLink Australia តាមលេខ 1800 437 222។ ម៉ោងធ្វើការរបស់យើងគឺ 9 ព្រឹក ដល់ 5 ល្ងាច ថ្ងៃចន្ទ ដល់ថ្ងៃ សុក្រ

អ្នកក៏អាចចូលមើលគេហទំព័រ TIS National សម្រាប់ព័ត៌មានដែលបានបកប្រែអំពីសេវាដែលផ្តល់ដោយ TIS National។ ចូលមើល៖ www.tisnational.gov.au

**ទូរសព្ទទៅ 1800 437 222 ឬចូលទៅកាន់គេហទំព័រ www.HepLink.au**

---

hepatitis australia

LiverWELL Incorporating HEPATITIS VICTORIA